ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៥៩
ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០
សាលដីកា
លេខ ១៣៩ "II"
ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកជំទាវ [redacted] ជាប្រធាន
២. ឯកឧត្តម [redacted] ជាចៅក្រម
៣. ឯកឧត្តម [redacted] ជាចៅក្រម
៤. ឯកឧត្តម [redacted] ជាចៅក្រម
៥. លោកជំទាវ [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៥៤៦ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១២៧ ក្រII "រ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញដែលមាន ៖

**-ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted]សម្បត្តិ ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិទួលគោក សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងមានទីលំនៅមុនពេលឃុំខ្លួន [redacted] ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ [redacted]" នៅរស់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ) (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

-មានលោក [redacted] បូរ៉ា ជាមេធាវីការពារក្តី។

២-ឈ្មោះ[redacted]សំណាង ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបររត់ម៉ូតូឌុប មានទីកន្លែងកំណើតនៅភូមិស្វាយ ឃុំបឹងសាលាខាង ស្រុកកំពង់ត្រាច ខេត្តកំពត និងមានទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ខេត្តកំពត ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted] "។" នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

-ជាប់ចោទពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៥ និង ០០នាទី កម្លាំងសមត្ថកិច្ចបានបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ០១ករណី នៅចំណុចភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត ដោយឃាត់ខ្លួនបានជនសង្ស័យ ចំនួន ០២នាក់ រួមមានឈ្មោះ[redacted]សម្បត្តិ ភេទប្រុស អាយុ ២៨ឆ្នាំ និងឈ្មោះ[redacted]សំណាង ភេទប្រុស អាយុ ៣៥ឆ្នាំ ដោយបានដកហូតថ្នាំញៀន ចំនួន ០៣កញ្ចប់ ទម្ងន់ ១០៥,៨៨ក្រាម ជញ្ជីងថ្លឹងអេឡិចត្រូនិចចំនួន ០១គ្រឿង រថយន្តសាំងយ៉ុង ០១គ្រឿង និងថង់ប្លាស្ទិចមួយចំនួន។ បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនជនសង្ស័យទាំងពីរនាក់ និងវត្ថុតាងមកអយ្យការដើម្បីចាត់ការតាមច្បាប់។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

**១**-ផ្តន្ទាទោសជនជាប់ចោទ ៖

១.ឈ្មោះ[redacted]សម្បត្តិ ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ កំណត់រយៈពេល ១៣(ដប់បី)ឆ្នាំ គិតពីថ្ងៃឃុំខ្លួន

២.ឈ្មោះ[redacted]សំណាង ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ កំណត់រយៈពេល ១០(ដប់)ឆ្នាំគិតពីថ្ងៃឃុំខ្លួន

ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២**-វត្ថុតាងមាន៖

-គ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សថ្លា ចំនួន ០៣កញ្ចប់តូច និង០២កញ្ចប់ធំ ទម្ងន់ ១០៥,៨៨ក្រាម (ក្នុងកញ្ចប់បិទជិត), ជញ្ជីងថ្លឹងគ្រឿងញៀន ០១គ្រឿង និងថង់ប្រកគ្រឿងញៀនមួយចំនួន ត្រូវរឹបអូស និងបំផ្លាញចោល យោងតាមបញ្ញត្តិមាត្រា ៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ២៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ឈ្មោះ [redacted] សម្បត្តិ ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១២៧ ក្រII "r" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១/ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ ទុកជាត្រឹមត្រូវតាមច្បាប់។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦៧ ជ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពត ទុកជាបានការ លើកលែងតែចំណុចទី១.១ ដែលផ្ដន្ទាទោសឈ្មោះ [redacted] សម្បត្តិ ដាក់ពន្ធនាគារកំណត់រយៈពេល ១៣(ដប់បី)ឆ្នាំ ត្រូវបន្ថយមកត្រឹម ១១(ដប់មួយ)ឆ្នាំវិញ។

-ចំណុចផ្សេងពីនេះរក្សាទុកដដែល។

៣/បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤/សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០។

-បើកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៥៤៦ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទ ឈ្មោះ [redacted] សម្បត្តិ ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១២៧ ក្រII "r" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញ សារណាការពារ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្ដីសន្និដ្ឋានថា នៅក្នុងសារណាចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ បានលើកឡើងថា សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួន ដោយសារខ្លួនបានសារភាពទទួលកំហុស មានឪពុកម្ដាយចាស់ជរា និងមានជីវភាពខ្វះខាត និងមិនសុខចិត្តការដែលតុលាការយកមាត្រា ៤០ មកផ្ដន្ទាទោសខ្លួន ដោយផ្អែកលើកោសល្យវិច័យរបស់



Scanned with CamScanner

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ការដែលជនជាប់ចោទ លើកយកលទ្ធផលកោសលវិច័យមកតវ៉ានេះ ពុំត្រឹមត្រូវទេ ដោយហេតុថា គ្រឿងញៀនដែលដកហូតបានមានទម្ងន់ ១០៥,៨៨ក្រាម ជាមេតំហ្វេតាមីន ដែលមានភាពសុទ្ធ ៧៩,៤៥% នៃទម្ងន់សរុបស្មើនឹង ៨៤,១២ក្រាម ដូចនេះ ការយកមាត្រា ៤០ មកអនុវត្ត គឺត្រឹមត្រូវហើយ។ តំណាងមហាអយ្យការយល់ឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ ពុំមានមូលហេតុ ដូចបានបញ្ញត្តិនៅក្នុងមាត្រា ៤១៩ ឡើយ គប្បីបដិសេធចោល។ ហេតុដូច្នេះ តំណាងមហាអយ្យការប្ដឹងសុំក្រុមប្រឹក្សាសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២៧ ក្រII "ទ" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ។ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់។

-ក្រឡាបញ្ជីបានអានសារណាការពារ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] សម្បត្តិ។

-លោកមេធាវី [redacted] ប៉ូវ៉ា បានធ្វើសេចក្ដីសន្និដ្ឋានការពារកូនក្ដីរបស់ខ្លួនថា ខ្លួនសុំទាញចំណាប់អារម្មណ៍ ចំពោះមាត្រា ៤៥ ដែលនៅក្នុងរឿងក្ដីនេះគឺបានចោទកូនក្ដីខ្លួនពីមាត្រា៤៥ និងមាត្រា ៤០ ហើយបើយោងតាមអង្គហេតុ និងចម្លើយរបស់ [redacted] សម្បត្តិ គឺគាត់អត់បានប្រព្រឹត្តបទល្មើសប្រើប្រាស់នោះទេ គឺគ្រាន់តែនៅពេលឃាត់ខ្លួនគាត់នោះ គឺគាត់មានកញ្ចប់ថ្នាំញៀននៅក្នុងខ្លួន ប៉ុន្តែគាត់មិនបានប្រើប្រាស់នោះទេ។ ចំពោះសាលដីកាលេខ ៣៣៣ IV ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ មេធាវីបានលើកឡើងថា អង្គហេតុប្រើប្រាស់នោះគឺជាអង្គហេតុចាស់ អញ្ចឹងបើសិនចង់ចោទប្រកាន់តាមមាត្រា ៤៥ សុំមេត្តាស៊ើបអង្កេតដោយឡែកមួយទៀត។ ចំពោះចំណុចពាក់ព័ន្ធនឹងសំអាងហេតុ ដើម្បីកាត់សេចក្ដីទៅលើ[redacted] សម្បត្តិ ថាបានប្រើប្រាស់គ្រឿងញៀន តាមមាត្រា ៤៥ បាន គឺត្រូវមានអង្គហេតុ ជាសំអាងក្នុងការសន្និដ្ឋានដើម្បីកាត់ទោសគាត់ ប៉ុន្តែចំណុចនេះមេធាវីមិនបានឃើញមានសំអាងជាក់លាក់ពាក់ព័ន្ធនឹងមាត្រា ៤៥ នោះទេ។ ដូច្នេះខ្លួនសុំឱ្យតុលាការដកចោលនៅការចោទប្រកាន់តាមមាត្រា ៤៥ ហើយនេះក៏ជាមូលហេតុមួយដែលនាំឱ្យមានការបន្ធូរបន្ថយទោសផងដែរ។ មួយវិញទៀត ពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌ ដែលគាត់ធ្វើការដកហូតគ្រឿងញៀន[redacted] សម្បត្តិ គឺឃើញតែពីរកញ្ចប់ធំនោះទេ ដោយមួយកញ្ចប់ទៀត គឺបានដកហូតចេញពីឈ្មោះ [redacted] សំណាង ដែលជាអ្នកចូលរួមប្រព្រឹត្ត ហើយបើសរុបចូលគ្នាទាំងអស់គឺមានបីកញ្ចប់ ។ ហើយចំពោះកំណត់ហេតុបិទ និងបើកដាក់ថាមានបីកញ្ចប់ ហើយសាលក្រម និងសាលដីកាក៏ថាមាន បីកញ្ចប់ ដែលចំណុចនេះ ខ្លួនសុំទាញចំណាប់អារម្មណ៍បន្តិចថា ប្រសិនបើចំនួនកញ្ចប់ខុសគ្នាតែមួយកញ្ចប់ នោះការដាក់ទោសក៏មានការប្រែប្រួលទៅតាមហ្នឹងដែរ។ ដូច្នេះសម្រេចវិញទីមួយ ដោយសារមាត្រា ៤៥ មិនបាននិយាយឱ្យច្បាស់លាស់នៅក្នុងសំអាងហេតុ។ ទីពីរ ដោយសារចំនួនកញ្ចប់មានការប្រែប្រួលមិនច្បាស់លាស់ ដែលនាំឱ្យមានការប្រែប្រួលពាក់ព័ន្ធនឹងទោស។ ក្នុងនាមខ្លួនជាមេធាវី



Scanned with CamScanner

ការពារផលប្រយោជន៍ឱ្យជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ សំណូមពរដល់លោកជំទាវប្រធានក្រុមប្រឹក្សាមេត្តាសម្រាលទោសតាមការស្នើសុំរបស់កូនក្តីខ្លួនផង។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយអំណានសារណាការពាររបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៩៤៦ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សម្បត្តិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា តាមសារណារបស់ជនជាប់ចោទ បានសុំឱ្យតុលាការកំពូល ផ្តល់ស្ថានសម្រាលដល់ខ្លួនតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ដោយសារខ្លួនទទួលស្គាល់កំហុស មានឪពុកម្តាយចាស់ជរា មានជីវភាពខ្វះខាត និងថាសាលាដំបូង និងសាលាឧទ្ធរណ៍សម្រេចផ្ទុយមាត្រា ៤០ នៃច្បាប់ស្តីពីគ្រឿងញៀន និងលទ្ធផលកោសលវិច័យ។

ការអះអាងនេះ ជាការមិនត្រឹមត្រូវទេ ពីព្រោះ តាមកំណត់ហេតុដកហូតវត្ថុតាង និងលទ្ធផលកោសលវិច័យបានបង្ហាញថា គ្រឿងញៀនដែលដកហូតបានមានចំនួន ១០៥,៨៨ក្រាម ជាមេតំហ្វេតាមីនដែលមានភាពសុទ្ធ ៧៩,៤៥% នៃទម្ងន់សរុបស្មើនឹង ៨៤,១២ក្រាម ដូចនេះឃើញថាការផ្តន្ទាទោសស្របនឹងមាត្រា ៤០ នៃច្បាប់ស្តីពីគ្រឿងញៀនហើយ។

៣-យល់ឃើញថា ការដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា នាពេលឃាត់ខ្លួនជនជាប់ចោទពុំបានប្រើប្រាស់គ្រឿងញៀនទេ តែបានបញ្ជាក់ថា ធ្លាប់ប្រើប្រាស់ពីមុនមក នៅកន្លែងផ្សេងដែលគប្បីដកហូតបទល្មើសនេះចេញ រីឯការជួញដូរគ្រឿងញៀន ជនជាប់ចោទទទួលស្គាល់ តែចំនួនកញ្ចប់គ្រឿងញៀនដែលបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ មានភាពពុំច្បាស់លាស់។ ចំណុចនេះតុលាការកំពូលពិនិត្យឃើញថា ចំពោះការប្រើប្រាស់គ្រឿងញៀន មានភស្តុតាងបញ្ជាក់ច្បាស់ថា ជនជាប់ចោទបានប្រើប្រាស់ ពីព្រោះមានកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ បញ្ជាក់ថា ជនជាប់ចោទមានសារធាតុញៀនក្នុងទឹកនោម ដែលនេះអាចកំណត់ថាជនជាប់ចោទពិតជាបានប្រើប្រាស់គ្រឿងញៀនពិតមែន។ ទាក់ទងនឹងចំនួនកញ្ចប់គ្រឿងញៀន ទោះបីជាការសរសេរចំនួនកញ្ចប់គ្រឿងញៀនមិនច្បាស់លាស់ពិតមែន ក៏ប៉ុន្តែទម្ងន់សរុបនៃគ្រឿងញៀន ដែលបានដកហូត មិនមានការប្រែប្រួលទេ គឺមានចំនួន ១០៥,៨៨ ក្រាម ដូចគ្នាទៅនឹងកំណត់ហេតុឃាត់ខ្លួនជាក់ស្តែង



Scanned with CamScanner

ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩, កំណត់ហេតុទទួលស្គាល់វត្ថុតាង និងកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង សុទ្ធតែបញ្ជាក់ថា ថ្នាំញៀនដែលដកហូតពីជនជាប់ចោទឈ្មោះ [redacted]សម្បត្តិ មានចំនួន ៣កញ្ចប់ធំ (តូច ២កញ្ចប់,ធំ១) មានទម្ងន់សរុប ១០៥,៨៨ ក្រាម ហើយតុលាការបានផ្តន្ទាទោសផ្អែកទៅលើទម្ងន់សរុបនៃគ្រឿងញៀន។ ដូចនេះ ទោសដែលតុលាការបានប្រកាសមានសមាមាត្រនឹងចំនួន និងប្រភេទនៃគ្រឿងញៀន តាមការកំណត់នៃបញ្ញត្តិច្បាប់ហើយ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១២៧ ក្រ.ព "ព" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ដែលសម្រេចមកនេះ ត្រឹមត្រូវហើយ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ៥៤៦ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ[redacted]សម្បត្តិ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២៧ ក្រ.ព "ព" ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការទាំងមូល។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១។

| | | |
|---|---|---|
| លោកជំទាវ | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| លោក | [redacted] | ជាក្រឡាបញ្ជី |

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម។

ថ្ងៃចន្ទ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

**បានឃើញ**

ថ្ងៃចន្ទ ១កើតខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner